# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ថ្លៃជាតក្រជាសអគ្រានុកូលដ្ឋាន និងថ្លៃតែមប្រិ៍សារពើពន្ធ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យលេខ ២៣ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតតែមប្រិ៍សារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ៧៦អនក្រ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែលំអ និង បំពេញបន្ថែមអនុក្រឹត្យស្តីពីការប្រមូលពន្ធតែមប្រិ៍
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

www.pheakdeylaw.com

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- យោងស្មារតីអង្គប្រជុំលើកទី១៤ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១.-**

ត្រូវបានកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទដូចខាងក្រោម ÷

ក- ខេត្តរតនគីរី-មណ្ឌលគីរី-ស្ទឹងត្រែង ព្រះវិហារ និង ឧត្តរមានជ័យ :

| | |
|---|---|
| - ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | កំណត់ ២០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្រអាពាហ៍ពិពាហ៍ | កំណត់ ១០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | កំណត់ ១០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់កំណើត | កំណត់ ១០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់មរណភាព | កំណត់ ១០០ រៀល ក្នុង ១ ទំព័រ |
| - សេចក្តីចម្លង ឬ សម្រង់ សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ | កំណត់ ១០០ រៀល ក្នុង ១ ទំព័រ |

ខ- ខេត្ត-ក្រុង ក្រៅពីខេត្តទាំង ០៥ ខាងលើ :

| | |
|---|---|
| - ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្រអាពាហ៍ពិពាហ៍ | កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់កំណើត | កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ |
| - សំបុត្របញ្ជាក់មរណភាព | កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ |
| - សេចក្តីចម្លង ឬ សម្រង់ សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ | កំណត់ ៤០០ រៀល ក្នុង ១ ទំព័រ |



www.pheakdeylaw.com

**មាត្រា ២ .-**

ថ្លៃតែមប្រើសារពើពន្ធសំរាប់បិទលើក្រដាសអត្រានុកូលដ្ឋានត្រូវបានកំណត់ដូចខាងក្រោម ៖

| | |
|---|---|
| - ពាក្យសុំរៀបអាពាហ៍ពិពាហ៍ | កំណត់ ១.០០០ រៀល ក្នុង ១ ច្បាប់ |
| - សេចក្តីចម្លង ឬ សម្រង់សំបុត្រកំណើត | កំណត់ ៣០០ រៀល ក្នុង ១ ច្បាប់ |
| - សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់កំណើត | កំណត់ ៣០០ រៀល ក្នុង ១ ច្បាប់ |
| - សេចក្តីចម្លង ឬ សម្រង់សំបុត្រអាពាហ៍ពិពាហ៍ | កំណត់ ១.៥០០ រៀល ក្នុង ១ ច្បាប់ |
| - សេចក្តីចម្លង ឬ សម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | កំណត់ ១.៥០០ រៀល ក្នុង ១ ច្បាប់ |
| - សេចក្តីចម្លង ឬ សម្រង់សំបុត្រមរណភាព | កំណត់ ៤០០ រៀល ក្នុង ១ ច្បាប់ |
| - សេចក្តីចម្លងឬ សម្រង់សំបុត្របញ្ជាក់មរណភាព | កំណត់ ៤០០ រៀល ក្នុង ១ ច្បាប់ |

**មាត្រា ៣ .-**

ចំណូលដែលឃុំ សង្កាត់ ប្រមូលបានពីការលក់ក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ត្រូវចាត់ជាចំណូលផ្ទាល់របស់ថវិកាឃុំ សង្កាត់ ។

**មាត្រា ៤ .-**

ក្រសួងមហាផ្ទៃមានភារកិច្ចបោះពុម្ពក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ សំរាប់ផ្គត់ផ្គង់ដល់អាជ្ញាធរដែលមានភារកិច្ចអនុវត្តការងារចុះបញ្ជីអត្រានុកូលដ្ឋាន ។

**មាត្រា ៥ .-**

ផ្អែកតាមស្មារតីនៃអនុក្រឹត្យនេះ ក្នុងករណីចាំបាច់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងបន្ថែមទៀត ។

**មាត្រា ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។



www.pheakdeylaw.com

**មាត្រា ៧ .-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២*

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី

**ស ខេង យូ ហុកគ្រី** | **គាត ឈន់**

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

__កន្លែងទទួល :__
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com